# បទបង្ហាញ
# ស្តីពី
# របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
# សម្រាប់កម្មករនិយោជិកដែលស្ថិតនៅបទ
# ប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៦
បង្ហាញដោយ លោក ហេង សុផាន់ណារិទ្ធ

# មាតិកា

I. គោលបំណង
II. វិសាលភាព
III. ភាគទាន
IV. តាវកាលិក
V. សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ
VI. តាវកាលិកចំពោះជំងឺរ៉ាំរ៉ៃ
VII. លក្ខខណ្ឌដើម្បីទទួលបានសេវាថែទាំសុខភាព
VIII. យន្តការទូទាត់សេវា

# I.គោលបំណង



បង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការជំងឺ និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលអាក់ខានការងារដោយការព្យាបាលជំងឺនិងការសម្រាកមាតុភាព។

# II.វិសាលភាព

- ដំណាក់កាលដំបូងអនុវត្តចំពោះ សមាជិក ប.ស.ស ដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាព ជនរងគ្រោះថ្នាក់ការងារដែលបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (ប្រពន្ធ ឬ ប្តី និងកូននៅក្នុងបន្ទុកផ្ទាល់នៃសាមីជន ជាសមាជិក ប.ស.ស ដែលទទួលមរណភាពដោយហានិភ័យការងារ)។
- ដំណាក់កាលបន្ទាប់ ត្រូវអនុវត្តចំពោះអ្នកនៅក្នុងបន្ទុកនៃសមាជិក ប.ស.ស ដែលរួមមាន ប្រពន្ធ ឬ ប្តី និងកូន។
- ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនេះ ត្រូវចាប់ផ្តើមចេញពី សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្ត្រ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឈានទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ តទៅ។

## III. ភាគទាន

- និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទាន ផ្នែកថែទាំសុខភាពជូនដល់បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)។
- អត្រាភាគទានផ្នែកថែទាំសុខភាពជាបន្ទុករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់ នៃ ប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។
- អត្រាភាគទានផ្នែកថែទាំសុខភាព ជាបន្ទុករបស់កម្មករនិយោជិត ត្រូវកំណត់ស្មើ នឹង ១,៣ (មួយក្បៀសបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំ ខែរបស់កម្មករនិយោជិត។
- ចំពោះអត្រាភាគទានដែលជាបន្ទុករបស់ឧត្តរជីវី ឬជនកំពុងទទួលបានប្រាក់ធនលាភ ត្រូវកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយនៃតាវកាលិករបស់សាមីខ្លួន។ CoCH

## IV.**គោលការណ៍**

តារាលិកថៃទាំសុខភាពរួមមាន *ការផ្ដល់កញ្ចប់តារាលិកសុខភាព និងសេវាបង្ការសុខភាពដែលបានកំណត់ ។*

១. ***កញ្ចប់តារាលិកសុខភាព*** : សេវាព្យាបាលថៃទាំវេជ្ជសាស្ត្រ សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។

**១.១ សេវាព្យាបាលថៃទាំវេជ្ជសាស្ត្រ**

**១.១.១ ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ**

- សេវាព្យាបាល ថៃទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (ធម្មតា) និងអាហារដែលផ្ដល់ដោយមូលដ្ឋានសុខាភិបាល។

# IV.តាចកាលិក ( ត )

**១.១.២. សេវាពិគ្រោះជំងឺក្រៅ**

- សេវាព្យាបាល ថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

**១.១.៣. សេវាសង្គ្រោះបន្ទាន់**

គឺជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើ ឡើងភ្លាមក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់ជនរងគ្រោះ។

**១.១.៤. សេវាព្យាបាលដោយស្នំ និងដោយចលនា។**

**១.១.៥. សេវាសម្រាលកូន សេវាព្យាបាល ថែទាំមុន និងក្រោយពេលសម្រាលកូន។**

**១.១.៦. សេវាស្តារនិតិសម្បទា**

# IV.គាំពារលិក (ឥ)

**១.២. សេវាបញ្ជូនជនរងគ្រោះ និងសេវាបញ្ជូនសព។**

**១.៣. ប្រាក់បំណាច់ប្រចាំថ្ងៃ** ត្រូវបានផ្តល់ជូនក្នុងពេលមានជំងឺ ឬជួបឧបទ្ទវហេតុផ្សេងៗ ដោយគិតបញ្ចូលទាំងចំណុច ១ ក្នុងប្រការ ៤ នៃប្រកាសនេះ។

**២. -សេវាបង្ការសុខភាព**

ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត ។

# V. សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ

១. ការព្យាបាលដោយមិនគិតថ្លៃដែលមានចែងនៅក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

(Free medical treatment shall determine in public health facility policy)

២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

Dental care (except extraction and pain kill)

៣. ការព្យាបាល និងការវះកាត់ប្តូរភេទ

(Sex interchange and transsexual surgery)

៤. ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ ( ខួរឆ្អឹង តំរងនោម ថ្លើម បេះដូង និងលំពែង...) Organs transplantation (bone marrow, kidney, liver, health and pancreas)

៥. សេវាបង្កកំណើតដោយសប្បនិម្មិត (Artificial Insemination in case of infertility)

៦. ការព្យាបាលដោយខ្លួនឯង (Self treatment)

៧.ការព្យាបាលឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាង្គកាយ

Cosmetic surgery and medical implants

៨. ឧបករណ៍ជំនួយភ្នែកសប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

Contact lens and eye- laser treatment

## V. សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ (ត)

៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន (Treatment of alcoholism or drug abuse)

១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត (Infertility treatment)

១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត (Artificial globe ocular operation)

១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង (Cardio vascular surgery)

១៣. ការលាងឈាម (Hemodialysis)

១៤. ការព្យាបាលមហារីកដោយសារធាតុគីមី (Chemo therapy for cancer treatment)

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើត្រូវបានផ្តល់ជូន។

## VI. តាមដានលិកចំពោះជំងឺរុំរ៉ៃ

- ជំងឺរុំរ៉ៃត្រូវបានកំណត់ចំនួន១៤ PCD
- ធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
- ប្រើប្រាស់តែឱសថសារវន្ត
- ចំពោះឱសថក្រៅពីសារវន្តជាបន្ទុករបស់អ្នកជំងឺ

# VII. លក្ខខណ្ឌដើម្បីទទួលបានសេវាថែទាំសុខភាព

1

**សេវាថែទាំវេជ្ជសាស្ត្រ**

កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកា ក្នុង ប.ស.ស សម្រាប់របបធានារ៉ាប់រងសុខភាព

បានចុះបញ្ជិកានៅក្នុង ប.ស.ស

បានបង់ភាគទានសម្រាប់ផ្នែកធានារ៉ាប់រងសុខភាពក្នុងរយៈពេល ០២ខែជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច ០៦ខែ ក្នុងអំឡុងពេល ១២ខែ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព

ក្នុងករណីដែលសមាជិកបានបង់ភាគទាន ០២ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានដោយសារការបញ្ចប់កិច្ចសន្យាការងារ សមាជិក មានសិទ្ធិនឹងទទួល សេវាព្យាបាលថែទាំវេជ្ជសាស្ត្ររយៈពេល ០២ខែ ថែមទៀត គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងារ

# ១. លក្ខខណ្ឌដើម្បីទទួលបានសេវាថែទាំសុខភាព

2

**ប្រាក់បំណាច់ប្រចាំថ្ងៃ**

- ប្រាក់បំណាច់ប្រចាំថ្ងៃជាប្រាក់ដែលផ្តល់ជូនសម្រាប់រយៈពេលអាក់ខានការងារដោយសារការធ្លាក់ខ្លួនមានជម្ងឺគ្រោះថ្នាក់ និងលំហែមាតុភាព
- បានបំពេញលក្ខខណ្ឌទាំងឡាយដូចក្នុងចំណុច ១
- ត្រូវសុំការអនុញ្ញាតច្បាប់ឈប់សម្រាកពីនិយោជកក្នុងអំឡុងពេលឈប់សម្រាកព្យាបាលជម្ងឺ
- បានបង់ភាគទានយ៉ាងតិច ៩ខែ ជាប់គ្នា ចំពោះប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាព

# ២. សិទ្ធិត្រូវទទួលបានសេវាថែទាំសុខភាព

**បានបំពេញលក្ខខណ្ឌ ១ និង ២**

ការព្យាបាលដោយឥតគិតថ្លៃនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស ក្នុងរយៈពេលមិនលើស ១៨០ ថ្ងៃក្នុងអំឡុងពេល ១២ខែ ទាំងរយៈពេលព្យាបាលក្នុង និងក្រៅមន្ទីរពេទ្យ

បានប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃអាក់ខានធ្វើការងារដោយសារការសម្រាកព្យាបាលថែទាំជម្ងឺ ឬរបួស តាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧ (ប្រាំពីរ)ថ្ងៃ ស្មើរ (៨ថ្ងៃឡើង)

បានប្រាក់ឈ្នួលពីនិយោជក ក្នុងករណីអាក់ខានធ្វើការងារដោយការឈប់សម្រាកព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាត្រឹម ០៧ថ្ងៃចុះ

ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីខ្លួន សម្រាប់រយៈពេល ៩០ថ្ងៃ នៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន

# ២. សិទ្ធិត្រូវទទួលបានសេវាថែទាំសុខភាព(ត)

**សេវាបញ្ជូនជនរងគ្រោះ/បញ្ជូនសព**

- សេវាបញ្ជូនជនរងគ្រោះផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់
- សេវាបញ្ជូនសពផ្តល់ជូនទៅតាមតម្លៃមូលដ្ឋានសុខាភិបាល ដែលទទួលស្គាល់ដោយ ប.ស.ស

# ៤. បែបបទ និងនិតិវិធីដើម្បីទទួលបានការព្យាបាលថែទាំវេជ្ជសាស្ត្រ

**បែបបទ និងនីតិវិធីដើម្បីទទួលបានការព្យាបាល ថែទាំវេជ្ជសាស្ត្រ**

- សមាជិក ប.ស.ស ត្រូវបង្ហាញអត្តសញ្ញាណដែលកំណត់ដោយ ប.ស.ស
- ករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលជិតបំផុត។
- ប.ស.ស នឹងទូទាត់សំណងលើចំណាយសម្រាប់ការព្យាបាលសង្គ្រោះបន្ទាន់ទៅឲ្យជនរងគ្រោះ ឬមន្ទីរពេទ្យ ដោយឈរលើមូលដ្ឋានគុណភាព និងតម្លៃរបស់មន្ទីរពេទ្យដែលមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស PPM 1 PPM 2
- ក្រៅពីករណីសង្គ្រោះបន្ទាន់ ប.ស.ស មិនទូទាត់សងឡើយ ចំពោះសមាជិក ប.ស.ស ព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ


Presenter

# សូមអគុណ


Five Way Puzzle People - Recolored
Piece 2
Add your text here.
Piece 1
Add your text here.
Piece 4
Add your text here.
Piece 3
Add your text here.
Piece 5
Add your text here.
Change the color of these images in PowerPoint 2007 and 2010. Choose Picture Tools/Format/Color